# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១៤ អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

******

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យ ប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃ គ្រឹះស្ថានសាធារណៈរដ្ឋបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៨/០៣៩ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៨ ស្តីពីរបបសន្តិសុខសង្គម សម្រាប់មន្ត្រីរាជការស៊ីវិល

-បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះ មានគោលដៅបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល សរសេរកាត់ថា «**ប.ជ.ស**»ដែលជាគ្រឹះស្ថានសាធារណរដ្ឋបាល ដើម្បីដាក់ឱ្យដំណើរការ គ្រប់គ្រង និង ធានាការបើកផ្តល់របបសន្តិសុខសង្គម ជូនមន្ត្រីរាជការស៊ីវិល និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុក ឱ្យបានទាន់ពេលវេលា ដើម្បីកាត់បន្ថយការលំបាក របស់មន្ត្រីរាជការស៊ីវិល និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ។

**ប.ជ.ស.** គឺជានីតិបុគ្គលនៃច្បាប់សាធារណៈ ដែលមានស្វ័យភាពផ្នែកហិរញ្ញវត្ថុ មានទីស្នាក់ការ កណ្តាលនៅរាជធានីភ្នំពេញ និងស្ថិតនៅក្រោមអាណាព្យាបាលផ្នែកបច្ចេកទេស របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងស្ថិតនៅក្រោមអាណាព្យាបាលផ្នែកហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ២ .-**

**ប.ជ.ស.** មានវិសាលភាពគ្របដណ្តប់លើមន្ត្រីរាជការស៊ីវិល និវត្តជន និងជនបាត់បង់សម្បទា វិជ្ជាជីវៈ ដែលមានស្ថានភាពចូលនិវត្តន៍ បាត់បង់សម្បទាវិជ្ជាជីវៈ មាតុភាព គ្រោះថ្នាក់ការងារ និងមរណភាព និងអ្នកនៅក្នុងបន្ទុក នៃជនទាំងនេះ ។

**ប.ជ.ស.** មានកាតព្វកិច្ចគ្រប់គ្រង និងធានាការបើកផ្តល់របបសន្តិសុខសង្គម ជូនមន្ត្រីរាជការស៊ីវិល និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ក្នុងករណីចូលនិវត្តន៍ បាត់បង់សម្បទាវិជ្ជាជីវៈ មាតុភាព គ្រោះថ្នាក់ការងារ និង មរណភាព និងអ្នកនៅក្នុងបន្ទុកនៃជនទាំងនេះ ។

## ជំពូកទី ២

## តួនាទី និងភារកិច្ច ប.ជ.ស.

**មាត្រា ៣ .-**

**ប.ជ.ស.** មានតួនាទីបជាអ្នកម្រើសេវារបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និវត្តជន ជនបាត់បង់ សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុក ស្របតាមស្មារតី និងខ្លឹមសារ ដែលមានចែងក្នុង គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ ។

**ប.ជ.ស.** មានភារកិច្ចដាក់ឱ្យដំណើរការ គ្រប់គ្រង និងធានាការបើកផ្តល់តាវកាលិក ជូនមន្ត្រីរាជការ ស៊ីវិល និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុក តាមគោលការណ៍អភិបាលកិច្ចល្អ មានតម្លាភាព ប្រសិទ្ធភាព និងមានការទទួលខុសត្រូវខ្ពស់ ។

**មាត្រា ៤ .-**

**ប.ជ.ស.** មានភារកិច្ចដូចខាងក្រោម៖

-ចាត់ចែង និងគ្រប់គ្រងរបបសន្តិសុខសង្គម ដោយអនុលោមតាមព្រះរាជក្រឹត្យលេខ នស /រកត/ ០១០៨/០៣៩ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៨ ស្តីពីរបបសន្តិសុខសង្គម សម្រាប់ មន្ត្រីរាជការស៊ីវិល

-គ្រប់គ្រងមូលនិធិ **ប.ជ.ស.** តាមគោលការណ៍អភិបាលកិច្ចល្អ

-ត្រួតពិនិត្យ និងវាយតម្លៃការចំណាយតាវកាលិក

-ស្រាវជ្រាវ និងរៀបចំបទប្បញ្ញត្តិសម្រាប់ **ប.ជ.ស.**

-សិក្សាស្រាវជ្រាវ និងធ្វើផែនការដើម្បីអភិវឌ្ឍន៍បច្ចេកទេសគ្រប់គ្រង និងរបបសន្តិសុខសង្គម ឱ្យបានសមស្របតាមស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ច។

-ប្រមូលភាគទានពីសមាជិក ទទួលថវិកាឧបត្ថម្ភពីរាជរដ្ឋាភិបាល និងទទួលជំនួយមនុស្សធម៌ ពីប្រភពផ្សេងៗទៀត

-ចាត់ចែង និងគ្រប់គ្រងការវិនិយោគមូលនិធិនៃ**ប.ជ.ស.**

-ទទួលខុសត្រូវ និង ធានាការបើកផ្តល់នូវតាវកាលិកទាំងឡាយ សម្រាប់សមាជិក**ប.ជ.ស.**

-សម្របសម្រួល និងរៀបចំឱ្យមានសេវាកម្មផ្នែកសុខាភិបាល និងសង្គមកិច្ចសម្រាប់ជាប្រយោជន៍ដល់សមាជិករបស់ខ្លួន។

## ជំពូកទី ៣

## រដ្ឋបាល ប.ជ.ស.

### ផ្នែកទី ១

### ក្រុមប្រឹក្សាភិបាល

**មាត្រា ៥ .-**

**ប.ជ.ស.** ដឹកនាំ និងគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាល ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១ រូប | ប្រធាន |
| ២- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១ រូប | អនុប្រធាន |
| ៣- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១ រូប | សមាជិក |
| ៤- តំណាងក្រសួងសុខាភិបាល | ១ រូប | សមាជិក |
| ៥- តំណាងក្រសួងយុត្តិធម៌ | ១ រូប | សមាជិក |
| ៦- តំណាងក្រសួងមហាផ្ទៃ | ១ រូប | សមាជិក |
| ៧- តំណាងក្រសួងអប់រំ យុវជន និងកីឡា | ១ រូប | សមាជិក |
| ៨- តំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | ១ រូប | សមាជិក |
| ៩- តំណាងមន្ត្រីរាជការស៊ីវិល | ១ រូប | សមាជិក |
| ១០- តំណាងនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ | ១ រូប | សមាជិក |
| ១១- នាយក **ប.ជ.ស** | ១ រូប | សមាជិកស្វ័យប្រវត្តិ។ |

**មាត្រា ៦ .-**

ក្រុមប្រឹក្សាភិបាលនៃ **ប.ជ.ស.** មានបេសកកម្មក្នុងការតម្រង់ទិស និងត្រួតពិនិត្យដំណើរប្រព្រឹត្តទៅរបស់ **ប.ជ.ស.** ។ ក្នុងក្របខ័ណ្ឌនៃបេសកកម្មនេះ ក្រុមប្រឹក្សាភិបាលមានភារកិច្ចដូចតទៅ ៖

-ពិនិត្យ និងសម្រេចលើគម្រោងថវិកាប្រចាំឆ្នាំរបស់ **ប.ជ.ស.**

-ពិនិត្យ និងសម្រេចលើរបាយការណ៍ប្រចាំឆ្នាំ ស្តីពីការងារគ្រប់គ្រង និងហិរញ្ញវត្ថុនៃ **ប.ជ.ស.**

-ពិនិត្យ និងសម្រេចលើបទបញ្ជាផ្ទៃក្នុង លក្ខន្តិកៈបុគ្គលិក និងរចនាសម្ព័ន្ធរដ្ឋបាលនៃ **ប.ជ.ស.**

-ពិនិត្យ និងសម្រេចរចនាសម្ព័ន្ធ និងភារកិច្ចរបស់អង្គភាពចំណុះ **ប.ជ.ស.**

-ពិនិត្យ និងកំណត់លើបែបបទនៃការជ្រើសរើស ការបញ្ឈប់ការងារ ការតែងតាំងការតម្លើងឋានៈ ការដាក់វិន័យ ឬផ្តល់លាភការដល់បុគ្គលិក **ប.ជ.ស.** ដែលនៅក្រៅក្របខ័ណ្ឌនៃមន្ត្រីរាជការស៊ីវិល

-ពិនិត្យ និងកំណត់លើបែបបទនៃការជ្រើសរើស ការបញ្ឈប់ពីការងារ ការតែងតាំងការតម្លើងឋានៈ ការដាក់វិន័យ ឬផ្តល់លាភការដល់បុគ្គលិក **ប.ជ.ស.** ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃមន្ត្រីរាជការស៊ីវិល ដើម្បីដាក់ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ពិនិត្យ និងសម្រេច

-សម្រេចចំនួនក្របខ័ណ្ឌនៃបុគ្គលិកដែលអនុញ្ញាត សម្រាប់**ប.ជ.ស.**

-សម្រេចអំពីកិច្ចសន្យាស្តីពីលទ្ធកម្មនៃ**ប.ជ.ស.**

-កំណត់កម្មវិធី និងផែនការវិនិយោគនៃ **ប.ជ.ស.**

-វាយតម្លៃលទ្ធផលការងារនៃ **ប.ជ.ស.** និងលើកវិធានការកែលម្អអនុវត្ត

-ពិនិត្យ និងលើកសំណើក្នុងការកំណត់អត្រាភាគទាន តាវកាលិក និងប្រភេទនៃរបបសន្តិសុខសង្គម តាមរយៈរដ្ឋមន្ត្រីក្រសួងអាណាព្យាបាល ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច ។

-សិក្សាស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍បច្ចេកទេសគ្រប់គ្រង និងរបបសន្តិសុខសង្គមឱ្យបានសមស្របតាមស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ច។

**មាត្រា ៧ .-**

ប្រធាន អនុប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលនៃ **ប.ជ.ស.** ត្រូវជ្រើសតាំងដោយផ្អែកលើលក្ខណសម្បត្តិ និង បទពិសោធរបស់ខ្លួន ក្នុងចំណោមមន្ត្រីរាជការបម្រើការងារយ៉ាងតិច ៥ (ប្រាំ)ឆ្នាំ ឬនិវត្តជន ឬក្នុងចំណោមឥស្សរជនខ្មែរ ដែលត្រូវបានទទួលស្គាល់ថា មានសមត្ថភាពខាងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច ឬនីតិសាស្ត្រ ហើយដែលមិនត្រូវបានផ្តន្ទាទោស ពីបទមជ្ឈិម ឬឧក្រិដ្ឋ។

ប្រធាន អនុប្រធាន និងសមាជិកនៃក្រុមប្រឹក្សាភិបាលនៃ **ប.ជ.ស.** ត្រូវតែងតាំងដោយអនុក្រឹត្យសម្រាប់អណត្តិ ៣ (បី)ឆ្នាំ រៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាតាមសំណើរបស់រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នដែលសមាជិកនោះតំណាងឱ្យ។ អាណត្តិនេះអាចបញ្ចប់ ឬបន្តទៀតបានតាមសំណើរបស់រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នដែលសមាជិកនោះតំណាងឱ្យ។

សមាជិកក្រុមប្រឹក្សាភិបាល ដែលជាតំណាងមន្ត្រីរាជការស៊ីវិល និងតំណាងនិវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវជ្រើសរើសដោយការបោះឆ្នោត ដែលរៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

**មាត្រា ៨ .-**

ក្រុមប្រឹក្សាភិបាល ត្រូវបើកអង្គប្រជុំយ៉ាងតិចមួយដង ក្នុងរយៈពេល ៣ (បី)ខែ ។ ទោះជាមានកំនត់ដូច្នេះក្តី ក្រុមប្រឹក្សាភិបាលអាចបើកអង្គប្រជុំបានគ្រប់ពេល អាស្រ័យដោយការចាំបាច់ ដើម្បីជាប្រយោជន៍នៃ **ប.ជ.ស.** តាមការអញ្ជើញរបស់ប្រធាន ឬតាមសំណើរបស់នាយកនៃ **ប.ជ.ស.** ឬតាមសំណើពីសមាជិកដែលមានចំនួន ៦ (ប្រាំមួយ) នាក់ យ៉ាងតិច ក្នុងចំណោមសមាជិកទាំងអស់ ។

ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាតែបញ្ហាទាំងឡាយណាដែលមានចុះក្នុងរបៀបវារៈ ។ របៀបវារៈនៃអង្គប្រជុំនីមួយៗ ព្រមទាំងឯកសារពាក់ព័ន្ធទាំងអស់ ត្រូវផ្ញើរជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ឱ្យបានមុន១០ (ដប់) ថ្ងៃប្រតិទិន មុនពេលបើកសម័យប្រជុំ ។ នាយកនៃ **ប.ជ.ស.** ត្រូវចាត់លេខាធិការកត់ត្រានៃអង្គប្រជុំក្រុមប្រឹក្សាភិបាល ។

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ជ.ស.** អាចប្រព្រឹត្តទៅបានលុះត្រាតែមានវត្តមានសមាជិកលើសពី ៥០ (ហាសិប)ភាគរយ ។ សមាជិករបស់ក្រុមប្រឹក្សាភិបាលដែលអវត្តមានពុំអាចត្រូវបានជំនួសបានទេ ។ ប្រសិនបើ កូរ៉ុមមិនគ្រប់ចំនួន ការប្រជុំត្រូវលើកទៅក្រោយ១៥ (ដប់ប្រាំ)ថ្ងៃប្រតិទិន ហើយត្រូវពិភាក្សាឡើងវិញលើរបៀបវារៈដដែល ។សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័ត ដោយសម្លេងភាគច្រើននៃសមាជិកវត្តមាន ។ ក្នុងករណីមានសម្លេងស្មើគ្នា សម្លេងរបស់ប្រធានក្រុមប្រឹក្សាភិបាលមានឧត្តមានុភាព ។

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវចូលរួមក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល តែគ្មាន សិទ្ធិបោះឆ្នោត ។

**មាត្រា ៩ .-**

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលក្នុងកិច្ចប្រជុំ ត្រូវកត់ត្រាទុកក្នុងកំណត់ហេតុ ហើយត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាល សមាជិកក្រុមប្រឹក្សាម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនៃ **ប.ជ.ស.** ក្នុងរយៈពេល ១០(ដប់)ថ្ងៃ យ៉ាងយូរ បន្ទាប់ពីថ្ងៃប្រជុំ ។

កំណត់ហេតុនៃកិច្ចប្រជុំ ត្រូវឆ្លុះបញ្ចាំងភាពពិតនៃការពិភាក្សារបស់អង្គប្រជុំ ហើយត្រូវចម្លងចូលបញ្ជី ដែលមានលេខរៀងទំព័រ តាមលំដាប់លំដោយ និងមានលេខកូដសម្គាល់ត្រឹមត្រូវ ។ កំណត់ហេតុនេះត្រូវចុះហត្ថលេខា ដោយលេខាធិការកត់ត្រា និងប្រធាននៃអង្គប្រជុំ ។ ក្នុងករណីមានការជំទាស់លើកឡើងដោយសមាជិកណាម្នាក់លើខ្លឹមសារនៃកិច្ចប្រជុំពេលមុន សម្រាប់ការប្រជុំលើកក្រោយរបស់ក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាការជំទាស់ទាំងនោះក្នុងកំណត់ហេតុ នៃការប្រជុំចុងក្រោយនេះផង ។

**មាត្រា ១០ .-**

លាភការរបស់សមាជិកក្រុមប្រឹក្សាភិបាល ត្រូវកំណត់ដោយប្រកាសរួម របស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល **ប.ជ.ស.** ។

**មាត្រា ១១ .-**

សមាជិកក្រុមប្រឹក្សាភិបាលនៃ **ប.ជ.ស.** ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ក្នុងករណីដូចខាងក្រោម ៖

-ទទួលមរណភាព ឬសុំលាលែង

-សមាជិករូបនោះវិកលចរិត ឬមានសតិវិបល្លាស ដោយមានការបញ្ជាក់ពីក្រសួងសុខាភិបាល

-សមាជិករូបនោះត្រូវបានតុលាការផ្តន្ទាទោស ពីបទមជ្ឈិម ឬឧក្រិដ្ឋ

-សមាជិករូបណាដែលបានជាប់ជាសមាជិករដ្ឋសភា ឬសមាជិកព្រឹទ្ធសភា

សមាជិកក្រុមប្រឹក្សាភិបាលរូបណា ដែលត្រូវបានតុលាការចោទប្រកាន់ ត្រូវបានព្យួរការងារជាបណ្តោះអាសន្ន។

ការជំនួសសមាជិកក្រុមប្រឹក្សាភិបាល ដែលបាត់បង់សមាជិកភា ព ត្រូវអនុវត្តដូចគ្នាតាមវិធីនៃការតាក់តែងដែរ។

## ផ្នែកទី ២

## អង្គការប្រតិបត្តិនៃ ប.ជ.ស.

**មាត្រា ១២ .-**

នាយក **ប.ជ.ស.** ត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

នាយក**ប.ជ.ស.** មានភារកិច្ចចាត់ចែង និងគ្រប់គ្រងការងារជាប្រក្រតីរបស់ **ប.ជ.ស.** ។

**មាត្រា ១៣ .-**

នាយក **ប.ជ.ស.** ត្រូវបានទទួលអំណាចចាំបាច់ សម្រាប់ដំណើការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពពេញលេញ ក្នុងការដឹកនាំគ្រឹះស្ថានស្របតាមច្បាប់ និងជាតំណាងរបស់ **ប.ជ.ស.** ក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់។ អំណាចនេះត្រូវបានប្រគល់ឱ្យ តាមរយៈបទបញ្ជាផ្ទៃក្នុងរបស់ **ប.ជ.ស.** និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ជ.ស.** ។

ក្នុងក្របខ័ណ្ឌនៃអំណាចនេះ នាយក **ប.ជ.ស.** មានភារកិច្ចសំខាន់ៗដូចតទៅៈ

-រៀបចំការប្រជុំរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ជ.ស.**

-រៀបចំឯកសារដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេច

-ចាត់ចែងអនុវត្តរាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលព្រមទាំងរាយការណ៍តាមដំណាក់កាលនីមួយៗ ជូនក្រុមប្រឹក្សាភិបាលអំពីសកម្មភាព និងលទ្ធផលការងាររបស់ **ប.ជ.ស.**

-ទទួលបន្ទុកគ្រប់គ្រង និងដឹកនាំ **ប.ជ.ស.** ផ្នែករដ្ឋបាល បច្ចេកទេស និងហិរញ្ញវត្ថុ

-រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ **ប.ជ.ស.** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេច

-គ្រប់គ្រងបណ្ដាភ្នាក់ងារ ឬមន្ត្រីគ្រប់រូបរបស់ **ម.ជ.ស.** ស្របតាមលក្ខខណ្ឌដែលកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង ឬកំណត់ដោយក្រុមប្រឹក្សាភិបាល

-លើកសំណើជូនក្រុមប្រឹក្សាភិបាល ពិនិត្យ និងសម្រេចចំពោះការជ្រើសរើស តែងតាំង តម្លើងឋានៈ ដាក់វិន័យ ឬផ្ដល់លាភការដល់បុគ្គលិកនៃ **ម.ជ.ស.** ដែលនៅក្រៅក្របខ័ណ្ឌនៃមន្ត្រីរាជការស៊ីវិល

-លើកសំណើជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ពិនិត្យ និងសម្រេចចំពោះការជ្រើសរើស តែងតាំង តម្លើងឋានៈ ដាក់វិន័យ ឬផ្ដល់លាភការដល់បុគ្គលិកនៃ **ម.ជ.ស.** ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃមន្ត្រីរាជការស៊ីវិល តាមរយៈក្រុមប្រឹក្សាភិបាល

-ធ្វើជាតំណាងនៃ **ម.ជ.ស.** ចំពោះការតវ៉ា ឬការប្ដឹងជំទាស់នានាទាក់ទងដល់ប្រតិបត្តិរបស់ **ម.ជ.ស.** និងទទួលខុសត្រូវចំពោះមុខច្បាប់ លើគ្រប់កិច្ចការពារផលប្រយោជន៍របស់ **ម.ជ.ស.** ។

នាយកនៃ **ម.ជ.ស.** មានសិទ្ធិផ្ទេរអំណាចខ្លះ ឬ ទាំងអស់ រួមទាំងផ្ទេរសិទ្ធិចុះហត្ថលេខាស្របតាមលក្ខខណ្ឌ ដែលបានកំណត់ដោយបទបញ្ជាផ្ទៃក្នុង ឬកំណត់ដោយក្រុមប្រឹក្សាភិបាល។

**មាត្រា ១៤ .-**

បុគ្គលិកអចិន្ត្រៃយ៍របស់ **ម.ជ.ស.** រួមមានមន្ត្រីរាជការស៊ីវិល ក្នុងក្របខ័ណ្ឌនៃក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ឬក្រសួងនានា ឬមន្ត្រីដែលជ្រើសរើសតាមសំណើ របស់នាយកនៃ **ម.ជ.ស.** ។ មន្ត្រីទាំងនេះត្រូវបានទទួលបន្តនូវបៀវត្ស និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស ដែលបានកំណត់ដោយមុខងារសាធារណៈពីអង្គភាពដើមរបស់ខ្លួន ដោយអនុលោមតាមបទបញ្ញត្តិទាំងឡាយនៃច្បាប់ និងអត្ថបទពាក់ព័ន្ធដទៃទៀត របស់មន្ត្រីរាជការស៊ីវិល និងអនុក្រឹត្យនេះ។

**ម.ជ.ស.** អាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា និងកម្មករ។ បុគ្គលិកទាំងនេះត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុងរបស់**ម.ជ.ស.** និងតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ស្របតាមច្បាប់ស្ដីពីការងារ។

បុគ្គលិកនៃ **ម.ជ.ស.** ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង នៃបទបញ្ញត្តិស្ដីពីបុគ្គលិក ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល។ ក្រុមប្រឹក្សាភិបាលកំណត់ ប្រាក់ កម្រៃលើកទឹកចិត្តចំពោះបុគ្គលិក ព្រមទាំងបែបបទនៃការទូទាត់ ដូចមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុង។

**មាត្រា ១៥ .-**

គណនេយ្យករនៃ **ម.ជ.ស.** ត្រូវតែងតាំងដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយមានការឯកភាពគ្នា ជាមួយរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ គណនេយ្យករនេះត្រូវស្ថិតនៅក្រោមឱវាទផ្ទាល់ របស់នាយកនៃ**ម.ជ.ស.** ។

**មាត្រា ១៦ .-**

រចនាសម្ព័ន្ធចាត់តាំងនៃ **ម.ជ.ស.** ត្រូវកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ**ម.ជ.ស.** ។

## ជំពូកទី ៤

## ការគ្រប់គ្រងហិរញ្ញវត្ថុ

## ផ្នែកទី ១
## កិច្ចការគណនេយ្យ

**មាត្រា ១៧ .-**

**ប.ជ.ស.** កាន់កាប់គណនេយ្យ ស្របតាមគោលការណ៍គណនេយ្យសាធារណៈ និងតាមវិធានគណនេយ្យ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ការិយបរិច្ឆេទគណនេយ្យ ចាប់ផ្តើមពីថ្ងៃទី ០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំដដែល ។

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវសម្រេចដោយក្រុមប្រឹក្សាភិបាលឱ្យបានមុនថ្ងៃទី ៣១ ខែមីនា នៃការិយបរិច្ឆេទបន្ទាប់ ។

របាយការណ៍ហិរញ្ញវត្ថុ ត្រូវសុំការយល់ព្រម ពីរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា ១៨ .-**

នាយកនៃ **ប.ជ.ស.** ជាអាណាប័កដើមខ្សែ របស់គ្រឹះស្ថានដែលត្រូវមានភារកិច្ចៈ

-ពិនិត្យប្រាក់ និងទូទាត់ចំណូល

-ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ

អាណាប័កដើមខ្សែអាចផ្ទេរសិទ្ធិឱ្យអាណាប័កផ្ទេរសិទ្ធិ ឬអាចបង្កើតនូវរជ្ជទេយ្យចំណូល ឬបុរេប្រទានបាន ដោយមានការយល់ព្រមពីគណនេយ្យករ ។

ការគ្រប់គ្រងហិរញ្ញវត្ថុ និងការកាន់កាប់គណនេយ្យ ត្រូវអនុវត្តដោយអនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់ **ប.ជ.ស.** ក្រោមការទទួលខុសត្រូវផ្ទាល់របស់គណនេយ្យករ ។ គណនេយ្យករនេះ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់កាប់ការងារ ។គណនេយ្យករនេះ ត្រូវចូលរួមប្រជុំរបស់ក្រុមប្រឹក្សាភិបាល ក្នុងឋានៈជាអ្នកពិគ្រោះយោបល់ តែឥតមានសម្លេងឆ្នោតឡើយ ។

គណនេយ្យករមានភារកិច្ចៈ

-ប្រមូលចំណាយ

-បើកប្រាក់ចំណាយ

-រក្សាទុក និងចាត់ចែងប្រើប្រាស់នូវមូលនិធិ និងធនធានរបស់**ប.ជ.ស.**

-រក្សាទុកនូវលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យ ។

គណនេយ្យករអាចផ្ទេរសិទ្ធិខ្លះទៅឱ្យអាជ្ញានុការរបស់ខ្លួន ។

**មាត្រា ១៩ .-**

នៅរៀងរាល់ឆ្នាំ យ៉ាងយូរត្រឹមថ្ងៃទី ៣០ ខែកញ្ញា ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ការយល់ព្រមលើកម្មវិធីអភិវឌ្ឍន៍ គម្រោងវិនិយោគ និងគម្រោងថវិកាប្រចាំឆ្នាំរបស់ **ប.ជ.ស.** តាមសំណើរបស់នាយកនៃ

គ្រឹះស្ថាននេះ ។ កម្មវិធី និងគម្រោងទាំងនេះ ត្រូវបញ្ជូនទៅសុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ផ្នែកទី ២
## មូលនិធិសម្រាប់ទ្រទ្រង់ ប.ជ.ស.

**មាត្រា ២០ .-**

ប្រភពធនធានរបស់ **ប.ជ.ស.** មានដូចខាងក្រោម ៖

-ធនធានដំបូងដែលរដ្ឋផ្តល់សម្រាប់បង្កើត **ប.ជ.ស.**

-ការផ្ទេរក្នុងលក្ខណៈជាអន្តរាគមន៍សាធារណៈ ដែលមានចែងក្នុងថវិការដ្ឋ ដូចជាឧបត្ថម្ភធនសម្រាប់ដំណើរការ និង ឧបត្ថម្ភជាមូលធន

-ប្រាក់ភាគទានរបស់រាជរដ្ឋាភិបាល

-ប្រាក់ភាគទានរបស់មន្ត្រីរាជការស៊ីវិល

-អំណោយ និងបច្ច័យទានផ្សេងៗ

-ផលចំណេញបានមកពីការវិនិយោគរបស់ **ប.ជ.ស.**

-ប្រភពធនធានដទៃទៀតដែល **ប.ជ.ស.** អាចទទួលបានស្របតាមច្បាប់ ។

អត្រាភាគទានខាងលើនេះ ត្រូវកំណត់ដោយប្រកាសរួម របស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីរាជរដ្ឋាភិបាល ។

## ផ្នែកទី ៣
## ការចំណាយ

**មាត្រា ២១ .-**

ការចំណាយរបស់ **ប.ជ.ស.** រួមមាន ៖

-ការចំណាយសម្រាប់ការងាររដ្ឋបាល

-ការបើកផ្តល់តាវកាលិកដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០១០៨/០៣៩ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៨ ស្តីពីរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការ ស៊ីវិល

-ការចំណាយលើការវិនិយោគជាប្រយោជន៍របស់ **ប.ជ.ស.**

-ការចំណាយសម្រាប់សកម្មភាពខាងសុខាភិបាល និងសង្គមកិច្ច ។

ទម្រង់ និងបែបបទនៃការចំណាយខាងលើ ត្រូវចែងលំអិតក្នុងប្រកាសរួម របស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ជ.ស.** ។

## ផ្នែកទី ៤

## ប្រាក់ត្រៀមបម្រុង

**មាត្រា ២២ .-**

ប្រាក់ត្រៀមបម្រុងសម្រាប់ផ្នែកសន្តិសុខសង្គមនីមួយៗ ត្រូវកំណត់ដោយប្រកាសរួម របស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីបានទទួលសំណើពីក្រុមប្រឹក្សាភិបាលនៃ **ប.ជ.ស.** ។

អត្រាភាគទានដែលមានចែងក្នុងមាត្រា២០ នៃអនុក្រឹត្យនេះ ត្រូវពិនិត្យឡើងវិញ ក្នុងករណីដែលប្រាក់ត្រៀមបម្រុង សម្រាប់ផ្នែកនីមួយៗ ធ្លាក់ចុះទាបជាងកម្រិតអប្បបរមា បន្ទាប់ពីបានទទួលយោបល់ពីក្រុមប្រឹក្សាភិបាលនៃ **ប.ជ.ស.** ។

ប្រាក់ត្រៀមបម្រុងសម្រាប់ផ្នែកនីមួយៗ ការវិនិយោគប្រាក់នេះ និងផលចំណេញដែលបានមកពីការវិនិយោគ ត្រូវចុះបញ្ជីគណនេយ្យដាច់ដោយឡែកពីគ្នា ។

## ផ្នែកទី ៥

## មូលនិធិបង្វិល

**មាត្រា ២៣ .-**

ត្រូវបង្កើតឱ្យមានមូលនិធិបង្វិលរួមមួយ សម្រាប់ការចំណាយនៃផ្នែកទាំងឡាយ របស់របបសន្តិសុខសង្គម ។ មូលនិធិនេះមិនត្រូវតិចជាង ២ (ពីរ)ដង នៃប្រាក់ចំណាយជាមធ្យមប្រចាំខែ របស់ **ប.ជ.ស.** នៅក្នុងអំឡុងឆ្នាំចុងក្រោយឡើយ ។

## ផ្នែកទី ៦

## ការវិភាគរបបសន្តិសុខសង្គម

**មាត្រា ២៤ .-**

**ប.ជ.ស.** ត្រូវធ្វើវិភាគហិរញ្ញវត្ថុ សម្រាប់របបសន្តិសុខសង្គម យ៉ាងយូរបីឆ្នាំម្តង ។ ក្នុងករណីដែលការវិភាគនេះបង្ហាញថា អាចមានគ្រោះថ្នាក់ដោយសារមានអតុល្យភាពហិរញ្ញវត្ថុ នៅក្នុងផ្នែកណាមួយ **ប.ជ.ស.** ត្រូវមានកាតព្វកិច្ចសិក្សារកដំណោះស្រាយស្នើ ទៅក្រសួងអាណាព្យាបាល ដើម្បី អាចធានាបាននូវនិរន្តភាពក្នុងដំណើរការរបស់ **ប.ជ.ស.** ។

រដ្ឋត្រូវផ្តល់ការឧបត្ថម្ភទ្រទ្រង់ឱ្យ **ប.ជ.ស.** បន្តនិរន្តរភាពនៅពេលជួបប្រទះឱនភាពថវិកា ។

# ជំពូកទី ៥

# អាណាព្យាបាល

## ផ្នែកទី ១

## អាណាព្យាបាលបច្ចេកទេស

**មាត្រា ២៥ .-**

ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយពីការប្រជុំក្រុមប្រឹក្សាភិបាលប្រចាំឆ្នាំ នាយកនៃ **ប.ជ.ស.** ត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវកម្មវិធីអភិវឌ្ឍន៍ និងគម្រោងថវិកាប្រចាំឆ្នាំដើម្បីសុំការយល់ព្រម ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

មានរយៈពេល ១ (មួយ)ខែ ចាប់ពីថ្ងៃដែលបានទទួលឯកសារ ត្រូវផ្តល់យោបល់របស់ខ្លួនជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេស មានរយៈពេល ២ (ពីរ) ខែ គិតចាប់ពីថ្ងៃដែលបានទទួលឯកសារ ដែលបញ្ជូនដោយនាយកនៃ **ប.ជ.ស.** ដើម្បីសម្រេចផ្តល់ការយល់ព្រមលើឯកសារទាំងនេះ ។

លិខិតយល់ព្រមរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវផ្ញើជូនទៅនាយកនៃ **ប.ជ.ស.** ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។នាយកនៃ **ប.ជ.ស.** ត្រូវបញ្ជូនព័ត៌មាននេះទៅក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មិនបានឆ្លើយតបក្នុងរយៈពេលកំណត់ទេនោះ កម្មវិធីអភិវឌ្ឍន៍ និងគម្រោងថវិកាប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព ។

ប្រសិនបើរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជំទាស់លើកម្មវិធីអភិវឌ្ឍន៍ ឬគម្រោងថវិកានេះ ប្រធានក្រុមប្រឹក្សាភិបាលត្រូវរៀបចំការប្រជុំក្រុមប្រឹក្សាភិបាលជាបន្ទាន់ ដើម្បីពិភាក្សា និងរិះរកមធ្យោបាយដោះស្រាយការជំទាស់នេះ ។

កម្មវិធីអភិវឌ្ឍន៍នៃ **ប.ជ.ស.** និងថវិកាចំណាយជាមូលធន មិនអាចឱ្យអនុវត្តបានឡើយ ក្នុងករណីដែលមានការជំទាស់លើកឡើង ដោយប្រធានស្ថាប័នអាណាព្យាបាលបច្ចេកទេស ។

ថវិកាចំណាយជាប្រចាំ អាចដាក់ឱ្យអនុវត្តត្រឹមលំនាំបំបែកជា ១២(ដប់ពីរ) ប៉ុណ្ណោះ នៅពេលដែលមានការជំទាស់ ពីប្រធានស្ថាប័នអាណាព្យាបាលបច្ចេកទេស ។ទោះជាយ៉ាង នេះក្តី ថវិកាចំណាយ សម្រាប់តាវកាលិកដែលត្រូវផ្តល់ឱ្យសមាជិក ត្រូវដាក់ឱ្យអនុវត្តបាន ។

**មាត្រា ២៦ .-**

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាចមានយោបល់ជំទាស់លើឯកសារស្តីពីកម្មវិធីអភិវឌ្ឍន៍ គម្រោងថវិកាប្រចាំឆ្នាំ និងកំណត់ហេតុនៃការប្រជុំក្រុមប្រឹក្សាភិបាល ។រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានរយៈពេល ១ (មួយ) ខែ សម្រាប់លើកឡើងនូវការជំទាស់ទាំងនោះ បន្ទាប់ពីបានទទួលឯកសារ ។

នាយក**ប.ជ.ស.** ត្រូវជូនព័ត៌មានទៅដល់ក្រុមប្រឹក្សាភិបាល នូវខ្លឹមសារនៃការជំទាស់ របស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។ ក្រុមប្រឹក្សាភិបាល ត្រូវធ្វើការពិភាក្សាឱ្យបានឆាប់បំផុតលើការជំទាស់ របស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងរិះរកមធ្យោបាយដោះស្រាយការជំទាស់ទាំងនោះ ។ប្រសិនបើក្រុមប្រឹក្សាភិបាលសម្រេចថា ពុំអាចយកជាការបាននូវការជំទាស់នោះ សេចក្តីសម្រេចនេះ ត្រូវបញ្ជាក់ពីមូលហេតុ ហើយត្រូវជម្រាបជូនដំណឹង ជាបន្ទាន់ជាលាយលក្ខណ៍អក្សរដល់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

**មាត្រា ២៧ .-**

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាអាចលុប ឬផ្អាកទុកសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ឬនាយកនៃ **ប.ជ.ស.** ក្នុងករណីដែលសេចក្តីសម្រេចនោះ ៖

- ផ្ទុយនឹងគោលដៅរបស់ **ប.ជ.ស.**
- ផ្ទុយនឹងច្បាប់ និងបទបញ្ជាផ្ទៃក្នុង

- ផ្ទុយនឹងបែបបទនៃការប្រជុំដែលមានចែងក្នុងមាត្រា ៨។

ការលុបចោល ឬការផ្អាកនេះ ត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយមានបញ្ជាក់ពីមូលហេតុដោយមានគំនិតផ្ទាល់ខ្លួន ឬតាមបណ្តឹងពីភាគីនានាដែលពាក់ព័ន្ធ។ ការលុបចោល ឬការផ្អាកសេចក្តីសម្រេចនេះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ដល់នាយក **ប.ជ.ស.** ។ នាយកនៃ **ប.ជ.ស.** ត្រូវជូនព័ត៌មាននេះ បន្តទៅក្រុមប្រឹក្សាភិបាល **ប.ជ.ស.** ក្នុងរយៈពេលដ៏ឆាប់បំផុត។

**មាត្រា ២៨ .-**

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាចចាត់ឱ្យធ្វើអធិការកិច្ច ឬការត្រួតពិនិត្យការងារក្នុង **ប.ជ.ស.** ក្នុងករណីដែលយល់ឃើញថាជាការចាំបាច់ ស្របតាមលក្ខខណ្ឌ និងបែបបទដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន។

## ផ្នែកទី ២

## អាណាព្យាបាលហិរញ្ញវត្ថុ

**មាត្រា ២៩ .-**

ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីការប្រជុំរបស់ក្រុមប្រឹក្សាភិបាល នាយកនៃ **ប.ជ.ស.** ត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាមានរយៈពេល ១ (មួយ)ខែ គិតចាប់ពីថ្ងៃទទួលបានឯកសារ ដើម្បីផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរយៈពេល ២ (ពីរ)ខែ គិតចាប់ពីថ្ងៃដែលទទួលបានឯកសារ ដែលបានបញ្ជូនមកដោយនាយកនៃ **ប.ជ.ស.** ដើម្បីសម្រេចផ្តល់ការយល់ព្រមលើឯកសារនេះ។

លិខិតយល់ព្រមដែលបានចុះហត្ថលេខាត្រឹមត្រូវ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអ្នកតំណាង ត្រូវផ្ញើទៅនាយក **ប.ជ.ស.** ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ នាយកនៃ**ប.ជ.ស.** ត្រូវជូនព័ត៌មាននេះទៅក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនឆ្លើយតបក្នុងរយៈពេលកំណត់ខាងលើ របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានយោបល់ជំទាស់លើរបាយការណ៍ ប្រធានក្រុមប្រឹក្សាភិបាល ត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាល ឱ្យបានឆាប់រហ័សបំផុត ដើម្បីរិះរកមធ្យោបាយដោះស្រាយការជំទាស់ទាំងនោះ។ការជំទាស់នេះត្រូវផ្អែកលើរបាយការណ៍ របស់សវនករឯករាជ្យ។

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ មិនអាចត្រូវបានសម្រេចយល់ព្រមបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពុំទាន់បានដោះស្រាយនៅឡើយនោះ។

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវមានទិដ្ឋាការពីសវនករឯករាជ្យ ដែលមានការទទួលស្គាល់ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ៣០ .-**

សេចក្តីសម្រេច ដូចរៀបរាប់ខាងក្រោមនេះ របស់ក្រុមប្រឹក្សាភិបាល ឬនាយកនៃ **ប.ជ.ស.** ត្រូវដាក់សុំការអនុញ្ញាតជាមុន ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តាមការផ្តល់យោបល់ពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុរួមមាន ៖

- សេចក្តីសម្រេចលើការលក់ ឬ ផ្ទេរអចលនទ្រព្យ
- សេចក្តីសម្រេច ស្តីពីការលើកលែងគណនេយ្យ ដែលមានទឹកប្រាក់លើសពីការកំណត់ របស់ប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សេចក្តីសម្រេច ស្តីពីកិច្ចព្រមព្រៀងខ្ចីប្រាក់ និងកិច្ចព្រមព្រៀងសម្រាប់ការធានា ឬលិខិតស្រដៀងគ្នានេះ ។

**មាត្រា ៣១ .-**

ត្រូវដាក់ឱ្យនៅអម **ប.ជ.ស.** នូវមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុមួយរូប ដែលត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនេះ មានភារកិច្ចដូចមានចែងនៅក្នុងអនុក្រឹត្យលេខ ៨១ អនក្រ .បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនូវការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិកា តាមក្រសួង អង្គភាពមូលដ្ឋាន តាមបណ្តាខេត្ត/ក្រុង និងតាមអង្គភាពសាធារណៈដែលមានលក្ខណៈរដ្ឋបាល។

ការគ្រប់គ្រងរបស់អណាប័កដើមខ្សែលើ **ប.ជ.ស.** ត្រូវស្ថិតក្រោមការត្រួតពិនិត្យ របស់អធិការដ្ឋានហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ការគ្រប់គ្រងរបស់គណនេយ្យករ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ របស់គណនេយ្យករកណ្តាលនៃរតនាគារជាតិ និងក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចាត់ចែងធ្វើការផ្ទៀងផ្ទាត់ អធិការកិច្ច ឬការត្រួតពិនិត្យលើ **ប.ជ.ស.** នៅពេលដែលយល់ថា ចាំបាច់ ស្របតាមលក្ខខណ្ឌ និងបែបបទដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន។

## ជំពូកទី ៦

## បទប្បញ្ញត្តិផ្សេងៗ

**មាត្រា ៣២ .-**

ទម្រង់បែបបទនៃការចុះឈ្មោះ ការបង់ប្រាក់ភាគទាន និងការផ្តល់តាវកាលិកសម្រាប់ផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម ត្រូវកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយមានការឯកភាព ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ជ.ស.** ។

**មាត្រា ៣៣ .-**

មូលនិធិរបស់ **ប.ជ.ស.** ត្រូវដាក់ចូលក្នុងគណនីនៅរតនាគារជាតិ ឬនៅធនាគារជាតិនៃកម្ពុជា ឬនៅធនាគារពាណិជ្ជកម្មផ្សេងៗ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលនៃ **ប.ជ.ស.** អាចសម្រេចឱ្យប្រើប្រាស់នូវប្រាក់ដែលលើស (ប្រាក់ដែលសល់ពីប្រាក់ត្រៀមបម្រុង) សម្រាប់ការវិនិយោគ បន្ទាប់ពីមានការយល់ព្រមពី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ៣៤ .-**

រដ្ឋធានាចំពោះតែបំណុលរបស់ **ប.ជ.ស.**ណាដែលមានការយល់ព្រមជាមុន ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ៣៥ .-**

ដំណាក់កាល វិសាលភាព នីតិវិធី និងកាលបរិច្ឆេទជាក់លាក់ សម្រាប់ការអនុវត្តផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា។

## ជំពូកទី ៧

## អន្តរប្បញ្ញត្តិ

**មាត្រា ៣៦ .-**

ចំពោះមុខនេះ រាជរដ្ឋាភិបាលទទួលបន្ទុករ៉ាប់រង នូវចំណែកនៃប្រាក់ភាគទានរបស់មន្ត្រីរាជការស៊ីវិល និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុក។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៣៧ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រីរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន មានភារកិច្ចអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣៨
- រាជកិច្ច

- ឯកសារ កាលប្បវត្តិ